


ព័ត៌មានកម្មវិធី SPCR

# ការប្រែប្រួលអាកាសធាតុ

ADB

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
ខែមីនា ឆ្នាំ២០១៧ លេខ៩

## វគ្គបណ្តុះបណ្តាលដល់អង្គការសង្គមស៊ីវិលស្តីពីការអនុវត្ត និងបច្ចេកទេសបន្សុំាក្នុងវិស័យមួយចំនួន

តាមរយៈយន្តការគាំទ្រសង្គមស៊ីវិល ដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ អង្គការភ្លែនអន្តរជាតិ បានបន្តផ្តល់វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពដល់អង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹង ១) កសិកម្មវៃឆ្លាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ ២) ភាពធន់អាកាសធាតុតំបន់ឆ្នេរ និង ៣) ភាពធន់នឹងអាកាសធាតុនៅទីក្រុង។




វគ្គបណ្តុះបណ្តាលរយៈពេល៤ ថ្ងៃអំពីកសិកម្មវៃឆ្លាតដែលធន់នឹងអាកាសធាតុ បានរៀបចំឡើងនៅខេត្តកំពង់ធំ តាំងពីខែតុលា ឆ្នាំ២០១៦ ដោយមានអង្គការដៃគូចំនួន ១៥ ដែលអនុវត្តការងារលើវិស័យកសិកម្ម មន្ត្រីរដ្ឋាភិបាលដែលអញ្ជើញមកពីស្ថាប័ន/មន្ទីរជុំវិញខេត្ត (២នាក់ជាមន្ត្រីពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៦នាក់អញ្ជើញមកពីការិយាល័យកសិកម្ម) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលអ្នកចូលរួមសរុបមានចំនួន ៣៨នាក់។ អ្នកសម្របសម្រួល២ នាក់ មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២នាក់មកពីក្រុមហ៊ុនឯកជន និង១នាក់ជាទីប្រឹក្សា ព្រមទាំងមានតំណាងមកពីធនាគារអភិវឌ្ឍន៍អាស៊ីម្នាក់ផងដែរ។

មេរៀនសំខាន់ៗដែលយកមកបណ្តុះបណ្តាលក្នុងពេលនោះមាន៖ ១. ផលប៉ះពាល់ និងការព្យាករណ៍អំពីការប្រែប្រួលនៅកម្ពុជា ២. តើកសិកម្មវៃឆ្លាតដែលធន់នឹងអាកាសធាតុ និងការចែករំលែកបទពិសោធន៍កសិកម្មវៃឆ្លាតដែលធន់នឹងអាកាសធាតុនៅក្នុងតំបន់ប្រទេសអាស៊ី ៣. ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ៤.សាកវប្បកម្ម ៥. ការគ្រប់គ្រងសត្វល្អិតដែលផ្តោតលើការគ្រប់គ្រងកត្តាចង្រៃចម្រុះ ៦. សាលារៀនស្រែកសិករ ៧. ការផលិតពូជស្រូវ ៨.ការចិញ្ចឹមសត្វ/បក្សី ៩. បច្ចេកវិជ្ជាសន្សំថាមពល (ឡជីវឧស្ម័ន ពន្លឺព្រះអាទិត្យ)។

វគ្គបណ្តុះបណ្តាលបានរៀបចំទស្សនកិច្ចសិក្សាចំនួន១ថ្ងៃ សិក្ខាកាមធ្វើជា ហើយរៀនសូត្របន្ថែមអំពីការចិញ្ចឹមមាន់ ការផលិតពូជស្រូវ និងសាកវប្បកម្ម (សិល្បៈនៃការដាំដុះ) ទៀតផង។

### មាតិកា

ប្រព័ន្ធស្រោចស្រពដំណក់ទឹក - បច្ចេកទេសបន្សុំា .......... ទំព័រ ៣
ក្រសួងផែនការរៀបចំកិច្ចប្រជុំស្តីពីការប្រមូលទិន្នន័យ ......... ទំព័រ ៣
នាយកដ្ឋានប្រែប្រួលអាកាសធាតុសិក្សាភាពងាយរងគ្រោះ .... ទំព័រ ៤
ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការវិនិយោគ........ ទំព័រ ៦
ឯកសារចំណេះដឹងដែលនឹងត្រូវបោះពុម្ពផ្សព្វផ្សាយ.............. ទំព័រ ៦

វគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃផ្សេងទៀតអំពីភាពធន់អាកាសធាតុតំបន់ឆ្នេរ បានរៀបចំឡើងនៅខេត្តកំពត ក្នុងខែមករា ឆ្នាំ២០១៧។ អ្វីដែលពិសេសនោះគឺកម្មវិធីបណ្តុះបណ្តាលបានរៀបចំឡើងនៅលើដីសហគមន៍នេសាទត្រពាំងសង្កែ ក្នុងភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត ដែលជាគម្រោងដៃគូដោយផ្ទាល់។ សិក្ខាកាមមកពីអង្គការដៃគូចំនួន ២ដែលអនុវត្តការងារនៅតំបន់ឆ្នេរ ក្នុងចំណោមអង្គការដៃគូទាំង ១៩ ហើយក៏មានការចូលរួមពីមន្ត្រីក្រសួងបរិស្ថាន មន្ទីរកសិកម្មខេត្ត រដ្ឋបាលជលផលខេត្តកំពត មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវវារីវប្បកម្មសមុទ្រខេត្តព្រះសីហនុ ទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូពាក់ព័ន្ធគម្រោងផងដែរ។



មេរៀនសំខាន់ៗដែលបានយកមកបណ្តុះបណ្តាលនាពេលនោះមាន៖ ១. ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការព្យាករណ៍អំពីអាកាសធាតុនៅកម្ពុជាក្នុងឆ្នាំ២០៥០ បង្ហាញដោយអង្គការភ្លែនអន្តរជាតិកម្ពុជា ២. អេកូទេសចរណ៍ និងការអភិរក្សគម្រោងនៅកោះរ៉ុង បង្ហាញដោយមូលនិធិកោះសង្សារ ៣. ការគ្រប់គ្រង និងការដាំស្មៅសមុទ្រ បង្ហាញមូលនិធិកោះសង្សារ ៤. ការរស់នៅជាមួយហានិភ័យគ្រោះមហន្តរាយ និងហានិភ័យអាកាសធាតុនៅខេត្តកំពត និងកែប ស្ត្រីដឹកនាំសហគ្រាសផលិតទឹក បង្ហាញដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ៥. អេកូទេសចរណ៍ និងគម្រោងអភិរក្សនៃសហគមន៍នេសាទត្រពាំងសង្កែ ការគ្រប់គ្រង និងការដាំព្រៃកោងកាង បង្ហាញដោយសហគមន៍នេសាទត្រពាំងសង្កែ ៦. ការដាំបន្លែនៅតំបន់ទឹកប្រៃ បង្ហាញដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៧. ការគ្រប់គ្រងធនធានសមុទ្របង្ហាញដោយខណ្ឌជលផលខេត្តកំពត ៨. ការចិញ្ចឹមត្រីសមុទ្រ បង្ហាញដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ ៩. ការថតរូប និងផលិតវីដេអូកម្រិតមូលដ្ឋាន បង្ហាញដោយអង្គការភ្លែនអន្តរជាតិកម្ពុជា និងអង្គការមូលនិធិសិទ្ធិកុមារ។

ដំណើរទស្សនកិច្ចបានធ្វើឡើងចំនួន ០១ថ្ងៃ នៅចន្លោះថ្ងៃទី២ ដើម្បីឱ្យអ្នកចូលរួមបានឃើញជាក់ស្តែងអំពីការអនុវត្តសកម្មភាពបន្សាំនៅតំបន់ឆ្នេរក្នុងខេត្តកំពត និងកែប ដូចជា៖ ១. សហគមន៍នេសាទត្រពាំងសង្កែ ដោយផ្តោតលើការដាំព្រៃកោងកាងឡើងវិញ សកម្មភាពល្បាត សហគមន៍នេសាទ ការដាំស្មៅសមុទ្រ អេកូទេសចរណ៍នៅសហគមន៍ ២. ភូមិព្រែកត្នោត ឃុំព្រែកត្នោត ដែលសិក្ខាកាមអាចទទួលបានចំណេះដឹងបន្ថែមអំពីការសម្ងួតបង្គារ ការដាំបន្លែ និងការយល់អំពីភាពងាយរងគ្រោះនៃសារជាតិប្រៃ/អំបិល ៣. ឃុំអង្កោលដែលសិក្ខាកាមបានចាប់អារម្មណ៍ខ្លាំងអំពីសហគ្រាសផលិតទឹកស្អាត ដែលដឹកនាំដោយស្ត្រី។ បន្ថែមលើការផលិត និងចម្រោះទឹកស្អាត សិក្ខាកាមបានទទួលចំណេះដឹងបន្ថែមអំពីទំនប់ការពារសារជាតិប្រៃ/អំបិល និងយន្តការផ្តួចផ្តើមគំនិតផ្សេងៗទៀត។

វគ្គបណ្តុះបណ្តាលរយៈពេល ០៣ ថ្ងៃផ្សេងទៀតស្តីអំពី ភាពធន់អាកាសធាតុនៅទីក្រុង បានធ្វើឡើងនៅចុងខែមីនា ឆ្នាំ២០១៧ នៅភ្នំពេញ ហើយអង្គការដៃគូចំនួន ០២ នៃអង្គការដៃគូទាំង១៩ ដែលគម្រោងរបស់គេនៅក្រុងបាត់ដំបង និងនៅភ្នំពេញ ព្រមទាំងសមាជិកសហគមន៍ មន្ត្រីសាលាក្រុង មន្ត្រីឃុំ/សង្កាត់ ពីតំបន់ទាំងពីរទាំងក្រុងបាត់ដំបង និងភ្នំពេញ ឬអ្នកចូលរួមសរុបប្រមាណជា ៣៨នាក់។ ក្រៅពីបុគ្គលិកអង្គការភ្លែនអន្តរជាតិកម្ពុជា តំណាងគណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ក្រុមហ៊ុនអាយសឹម (ICEM) អង្គការភីន (PIN) ព្រមទាំងមន្ត្រីមកពីសាលាក្រុងបាត់ដំបងផងដែរ និងការចែករំលែកបទពិសោធន៍ពីសគមន៍ស្ទឹងមានជ័យលើការគ្រប់គ្រងកាកសំណល់។



មេរៀនសំខាន់ៗនៃវគ្គបណ្តុះបណ្តាលនេះរួមមាន៖ ១. ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការទស្សន៍ទាយអំពីគ្រោះមហន្តរាយនៅតំបន់ទីក្រុង ២. បទបង្ហាញអំពីការធ្វើនគរូបនីយកម្មទីក្រុង ភាពងាយរងគ្រោះ និងភាពក្រីក្ររបស់ប្រជាពលរដ្ឋរស់នៅទីក្រុងនៅកម្ពុជា និងគ្រោះថ្នាក់ដោយសារទឹកជំនន់ បង្ហាញដោយអង្គការភីន (PIN) ៣. លំនៅស្ថានធន់ដែលបង្ហាញដោយអង្គការលំនៅដ្ឋានមនុស្សជាតិ ដែលជាអង្គការដៃគូជាមួយអង្គការសមត្ថភាពខ្ញុំ (SKO) ក្រោមគម្រោងយន្តការគាំទ្រសង្គមស៊ីវិល ៤. ការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងកាកសំណល់នៅសហគមន៍ នៅស្ទឹងមានជ័យ បង្ហាញដោយអង្គការមូលដ្ឋានសហគមន៍ (CBO) ៥. ផែនការអនាម័យទីក្រុង បង្ហាញដោយអ្នកជំនាញគម្រោងទឹកស្អាត និងអនាម័យ ៦. ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវដែលធន់ ដែលបង្ហាញដោយក្រុមហ៊ុនICEM ៧. កាកសំណល់ និងការគ្រប់គ្រងលូទឹកស្អុយក្នុងខេត្តបាត់ដំបង ដែលបង្ហាញដោយមន្ត្រីក្រុង ៨. ការណែនាំការតំរង់ទិស និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យ

គ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ បង្ហាញដោយមន្ត្រីគជអប (NCDD-s)។

វគ្គបណ្ដុះបណ្ដាលនឹងរួមបញ្ចូលទាំងដំណើរទស្សនកិច្ចសិក្សានៅតំបន់អនុវត្តការងាររបស់អង្គការសមត្ថភាពខ្ញុំ នៅសហគមន៍ស្ទឹងមានជ័យ ក្នុងខណ្ឌច្បារអំពៅ ក្នុងរាជធានីភ្នំពេញផងដែរ។

## ប្រព័ន្ធស្រោចស្រពដំណក់ទឹក--បច្ចេកទេសបន្សាំនឹងការប្រែប្រួលអាកាសធាតុ

កសិករកម្ពុជាកាន់តែយល់ដឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅលើការដាំដុះដំណាំរបស់ពួកគាត់។ កសិករដឹងថាជីវភាពរស់នៅរបស់ពួកគាត់ងាយរងគ្រោះ ហើយពួកគាត់ត្រូវការរកវិធីសាស្ត្របន្សាំនៅពេលបច្ចុប្បន្ន និងពេលអនាគត។ បច្ចេកទេសដែលអាចជួយសម្រួលដល់ជីវភាពរស់នៅរបស់ពួកគាត់ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុស្រប នឹងការធ្វើឱ្យប្រសើរឡើងការដាំដុះដំណាំគឺប្រព័ន្ធស្រោចស្រពដំណក់ទឹក។



អ្នកស្រី ឡាយ ហេង នៅភូមិប្រម៉ាត់ដី ក្នុងខេត្តត្បូងឃ្មុំ ជាកសិករម្នាក់ដែលបានសម្រេចចិត្តបន្សាំ នឹងការប្រែប្រួលអាកាសធាតុដោយប្រើប្រាស់ប្រព័ន្ធស្រោចស្រពដំណក់ទឹក។ អ្នកស្រី ហេង បានឱ្យដឹងថា "ប្រព័ន្ធស្រោចស្រពដំណក់ទឹក ជួយកាត់បន្ថយការបាត់បង់ទឹកដោយសារការហួត និងធ្វើឱ្យទឹកហូរយឺតៗចូលទៅក្នុងឫសដំណាំពោត ដែលនេះជាវិធីសាស្ត្រល្អក្នុងការស្រោចទឹកដំណាំ។" គាត់បានមានប្រសាសន៍បន្ថែមទៀតថា បច្ចេកទេសនេះ គឺងាយស្រួលតំឡើង សន្សំសំចៃទឹក និងកាត់បន្ថយកម្លាំងពលកម្មក្នុងការស្រោចទឹកដំណាំ។ អ្នកស្រី ហេង បានប្រើប្រាស់ពេលវេលា ដែលសល់ពីការស្រោចទឹកដំណាំ ទៅរកប្រាក់ចំណូលបន្ថែមផ្សេងៗទៀត។



កសិករនៅខេត្តកំពង់ធំ ក៏យល់ឃើញថាប្រព័ន្ធស្រោចស្រពដំណក់ទឹក ជាបច្ចេកទេសមានប្រសិទ្ធភាពបន្សាំក្នុងលក្ខខណ្ឌរាំងស្ងួតដោយសារការប្រែប្រួលអាកាសធាតុ។មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាន និងកំពុងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្សព្វផ្សាយការយល់ដឹងពីការប្រើប្រាស់ប្រព័ន្ធស្រោចស្រពដំណក់ទឹកសម្រាប់ដំណាំរយៈពេលខ្លីនិង បច្ចេកទេសសន្សំសំចៃទឹក ដូចជាគ្របប្លាស្ទិកលើដីដើម្បីរក្សាសំណើមបន្ទាប់ពីដំណាំត្រូវបានដាក់ដាំរួច។



ស្ត្រីភាគច្រើនជាកសិករ និងប្រឈមការចំណាយកម្លាំង និង ពេលវេលាច្រើននៅពេលមានការខ្វះខាតទឹក -- បច្ចេកទេសនេះជួយគ្រប់គ្រងទឹកឱ្យកាន់តែមានប្រសិទ្ធភាព ពិសេសមានប្រយោជន៍ចំពោះស្ត្រី។

## ក្រសួងផែនការរៀបចំកិច្ចប្រជុំស្ដីពីការប្រមូលទិន្នន័យ ការផ្សព្វផ្សាយ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការបន្សាំការប្រែប្រួលអាកាសធាតុ

កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ក្រសួងផែនការបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធលើការត្រួតពិនិត្យការបន្សាំការប្រែប្រួលអាកាសធាតុ។ កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងជាផ្នែកមួយនៃដំណើរការពិគ្រោះយោបល់ពហុដៃគូ ស្ថិតក្រោមកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ និងបានបង្កើតជាវេទិកាសម្រាប់ក្រសួងផែនការ និងក្រសួងវិស័យពាក់ព័ន្ធដើម្បីទាញយកសមាសភាគមូលដ្ឋានទិន្នន័យដែលមានស្រាប់ និងតម្រូវការដែលត្រូវបង្កើតប្រព័ន្ធប្រមូលទិន្នន័យ និងមូលដ្ឋានទិន្នន័យសម្រាប់ការរៀបចំផែនការ និងគ្រប់គ្រងកម្មវិធីបន្សាំ និងកម្មវិធីវិនិយោគ។



កិច្ចប្រជុំនេះមានអ្នកចូលរួមចំនួន៣៨នាក់ ដែលអញ្ជើញមកពីវិទ្យាស្ថានជាតិស្ថិតិ អគ្គនាយកដ្ឋានផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងសមាជិកមួយចំនួនទៀតនៃក្រុមការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងផែនការ។

ការវិភាគមូលដ្ឋានទិន្នន័យដែលមានស្រាប់ប្រើសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃដោយរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗបានផ្តល់ឱ្យអ្នកចូលរួមកាន់តែយល់ដឹងពីទិន្នន័យដែលមាន កង្វះខាតទិន្នន័យ ការប្រើប្រាស់ទិន្នន័យ និងសូចនាករដើម្បីតាមដានប្រសិទ្ធភាព និងវឌ្ឍនភាពនៃការវិនិយោគបន្សាំ។

អ្នកចូលរួមក៏បានលើកផងដែរពីចំណុចមួយចំនួននៃបញ្ហាប្រឈមជាទូទៅទាក់ទងនឹងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ ការប្រមូលទិន្នន័យ និងការតាមដាននិងវាយតម្លៃដូចជា ៖

- ខ្វះធនធាន ហិរញ្ញវត្ថុ និងបច្ចេកទេស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- គុណភាពនៃទិន្នន័យរដ្ឋបាលគឺទាបជាងតម្រូវការ និងវិសាលភាពគ្របដណ្តប់នៅមានកម្រិត
- ខ្វះខាតទិន្នន័យលម្អិតតាមកម្រិតដោយអវត្តមាននូវការចុះសិក្សាអង្កេតមួយចំនួន និងចំនួន សំណាកដែលកំណត់មានទំហំតូចសម្រាប់ការអង្កេតជាតំណាងថ្នាក់ជាតិដែលមានស្រាប់
- ខ្វះខាតបុគ្គលិកជំនាញ ជាពិសេសបុគ្គលិកស្ថិតិនៅទីស្នាក់ការកណ្តាល និងថ្នាក់ខេត្ត
- ប្រព័ន្ធស្ថិតិត្រូវការពង្រឹងបន្ថែមទៀតសម្រាប់ការប្រមូលព័ត៌មាន ការវិភាគ ការផ្សព្វផ្សាយ
- ការគ្រប់គ្រង និងការចែករំលែក
- ធនធានមានកម្រិតក្នុងការថែរក្សាស្ថានីយវាស់ស្ទង់ និងបង្ហាញព័ត៌មានទឹកភ្លៀង
- មិនមានមូលដ្ឋានទិន្នន័យ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវបានបង្កើតឡើង សម្រាប់គម្រោងវិនិយោគបន្សាំ។




ជំហានបន្ទាប់នៃគម្រោងជំនួយបច្ចេកទេសការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (កញ្ចប់C) នឹងពិនិត្យមើលឡើងវិញនូវធនធានទិន្នន័យមូលដ្ឋានដែលមានស្រាប់ និងកំណត់ភាពប្រឈម និងគាំទ្រដល់ក្រសួងផែនការក្នុងការរៀបចំយុទ្ធសាស្រ្ត និងជំហានបន្ទាប់ដើម្បីធ្វើឱ្យប្រសើរឡើងប្រព័ន្ធតាមដាន ត្រួតពិនិត្យព័ត៌មានបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

## នាយកដ្ឋានប្រែប្រួលអាកាសធាតុសិក្សាភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការវិភាគផលប៉ះពាល់បឋមលើបរិស្ថាន និងសង្គម

ចាប់ពីថ្ងៃទី១៧ខែមករា ដល់ថ្ងៃទី១៦ខែកុម្ភៈឆ្នាំ២០១៧ ក្រុមការងារបច្ចេកទេសការបន្សាំនឹងការប្រែប្រួលអាកាសធាតុបាន និងកំពុងចុះសិក្សាភាពងាយរងគ្រោះ ពីការប្រែប្រួលអាកាសធាតុ និងការធ្វើផែនការបន្សាំ ព្រមទាំងការវិភាគផលប៉ះពាល់បឋមលើបរិស្ថាន និងសង្គមដើម្បីរៀបចំគម្រោងវិនិយោគដែលមានសក្តានុពលមួយចំនួននៅខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ព្រៃវែង កំពង់ធំ កំពង់ឆ្នាំង និងត្បូងឃ្មុំ ។ ការសិក្សានេះ ជាជំហានមួយក្នុងការសិក្សាលម្អិតពីលទ្ធភាព កសាងសំណើគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្តោតលើវិស័យកសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍទីក្រុងដើម្បីស្វែងរកមូលនិធិពីសហគមន៍អន្តរជាតិសម្រាប់ការអនុវត្តសកម្មភាពបន្សាំ។



ការចុះសិក្សាទាំងនេះដឹកនាំ និងសម្របសម្រួលដោយឯកឧត្តមសាស្រ្តាចារ្យបណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធីយុទ្ធ

សាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) និងសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរពាក់ព័ន្ធនៅតាមខេត្ត ស្រុក ឃុំ និងភូមិ។

គោលបំណងនៃបេសសកកម្មនេះ គឺដើម្បី៖

- វាយតម្លៃពីភាពងាយរងគ្រោះគម្រោងស្តារ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដំណាក់ឈើក្រំ ដំណាក់កាលទី២ក្នុងខេត្តបាត់ដំបង និងពោធិ៍សាត់ទៅលើហេដ្ឋារចនាសម្ព័ន្ធ និងបទអន្តរាគមន៍ទៅនឹងការប្រែប្រួលអាកាសធាតុតាមរយៈការប្រមូលទិន្នន័យដើមគ្រា វាយតម្លៃភាពងាយរងគ្រោះ និងបង្ហាញឱ្យឃើញពីជម្រើសបន្សាំ និងធ្វើផែនការ
- ប្រមូលទិន្នន័យសម្រាប់ការវាយតម្លៃបឋមលើហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ប្រមូលទិន្នន័យសម្រាប់ការរៀបចំកសាងសំណើគម្រោងបន្សាំ



ក្រុមការងារបានចុះទៅពិនិត្យមើល និងប្រមូលព័ត៌មានពាក់ព័ន្ធពាក់ព័ន្ធកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដែលមានស្រាប់ដូចជាប្រឡាយមេ និងប្រឡាយរងស្រោចស្រពស្រែ អាងស្តុកទឹក ការដាំដំណាំបន្លែចម្រុះដោយប្រើប្រព័ន្ធស្រោចស្រពដំណក់ទឹក ប្រព័ន្ធលូបង្ហូរ និងផ្លូវលំជនបទ។ ការសិក្សាពីលទ្ធភាពលម្អិតគម្រោងបន្សាំ ដើម្បីវាយតម្លៃភាពងាយរងគ្រោះ និងរៀបចំសំណើគម្រោងមានដូចខាងក្រោម៖

(១) ស្តារ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដំណាក់ឈើក្រំនៅខេត្តបាត់ដំបង និងពោធិ៍សាត់

(២) ការអភិវឌ្ឍប្រព័ន្ធសាកវប្បកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅខេត្តកំពង់ធំ

(៣) ការគ្រប់គ្រងទឹកដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងផលិតកម្មកសិកម្មនៅខេត្តព្រៃវែង

(៤) ការស្តារឡើងវិញនៃប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធលូបង្ហូរទឹកកំពង់សីមាក្នុងក្រុងបាត់ដំបង

(៥) ការបង្កើនភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធជនបទ និងការលើកកម្ពស់ជីវភាពសហគមន៍នៅស្រុកកំពង់លែងក្នុងខេត្តកំពង់ឆ្នាំង និង

(៦) ការធ្វើប្រសិទ្ធិកម្មផ្លូវជនបទ និងការកសាងប្រព័ន្ធធារាសាស្ត្រ និងអាងស្តុកទឹកសហគមន៍ដែលធន់នឹងអាកាសធាតុ

សូមបញ្ជាក់ថា នេះគឺជាជំហានទីបីក្នុងចំណោមជំហានសំខាន់ៗទាំងប្រាំ ក្នុងការសិក្សាលម្អិតពីលទ្ធភាពកសាងសំណើគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។



*ការប្រជុំជាមួយអជ្ញាធរដើម្បីចុះសិក្សាលម្អិតពីលទ្ធភាពកសាងសំណើគម្រោងបន្សាំក្នុងខេត្តកំពង់ឆ្នាំង*

## ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ

កម្មវិធី យុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ដែលគាំទ្រដោយមូលនិធិវិនិយោគអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជាកំពុងផ្តួចផ្តើមដាក់បញ្ចូលវិធានការ សម្រាប់ភាពធន់នឹងអាកាសធាតុទៅក្នុង គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដែលគ្រប់គ្រងដោយក្រសួងសាធារណការនិងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ។

ខាងក្រោមនេះ ជាសកម្មភាពការងារចាប់ផ្តើមនាពេលបច្ចុប្បន្ន៖

### ធនធានទឹក

- សាងសង់ទំនប់ និងទ្វារទឹក(ពោធិតានុន បាក់ដាវ និងស្រុក) នៅស្រុកកំពង់លែងក្នុងខេត្តកំពង់ឆ្នាំង
- សាងសង់មណ្ឌលសង្គ្រោះបន្ទាន់ចំនួន១និងតំបន់ទីទួលសុវត្ថិភាពចំនួន៦ នៅស្រុកកំពង់លែង ក្នុងខេត្តកំពង់ឆ្នាំង
- ស្តារបឹងដើម្បីផ្គត់ផ្គង់ទឹកប្រើប្រាស់ឱ្យគ្រប់គ្រាន់ក្នុងកំឡុងរដូវប្រាំង នៅស្រុកទឹកផុសក្នុងខេត្តកំពង់ឆ្នាំង
- ឯកសារដាក់ដេញថ្លៃ ដើម្បីរៀបចំនិងសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹក នៅស្រុកកំពង់លែងក្នុងខេត្តកំពង់ឆ្នាំង

### ហេដ្ឋារចនាសម្ព័ន្ធផ្លូវ

- ផ្លូវខេត្តដែលធន់នឹងអាកាសធាតុប្រវែង១៥៧គីឡូម៉ែត្រ ឆ្លងកាត់ផ្លូវ (N13, N53, 150B, 151B,314D) កំពុងត្រូវបានសាងសង់។ ដើមឈើនឹងត្រូវដាំតាមជើងទេរផ្លូវដើម្បីការពារការហូរច្រោះ និងការរអិលបាក់ដី។
- ផ្លូវលំជនបទ និងកំពង់ចម្លង កំពុងត្រូវបានសាងសង់នៅខេត្តកំពង់ចាម។

## ឯកសារចំណេះដឹងដែលនឹងត្រូវបោះពុម្ពផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ក្នុងពេលឆាប់ៗនេះ



















**ព័ត៌មានបន្ថែម៖**

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធី

លោក មាស សុផល នាយកដឹកនាំកម្មវិធី

លោក អ៊ូ ច័ន្ទជារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

នាយកដ្ឋានប្រែប្រួលអាកាសធាតុ

អគារមរតកតេជោ ឡូត៍លេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ៖ ០៥៥ ២៣ ៥៣១៤ ៧៧៧

អ៊ីម៉ែល៖ adbspcrta8179@gmail.com

គេហទំព័រ៖ http://www.spcrcambodia.org/kh/